មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែធ្នូ ឆ្នាំ២០១៣

គោលនយោបាយសន្ទនៈ សេរីភាពបញ្ចេញមតិនៅក្នុងព្រះរាជាណាចក្រ



ឧបត្ថម្ភដោយ ៖

សហភាពអឺរ៉ុប

British Embassy
Phnom Penh

សំណួរ និងមតិចូលរួម

ប្រសិនបើអ្នកមានសំណួរ ឬក៏ចង់បានព័ត៌មានផ្សេងៗ ឬប្រសិនបើអ្នកចង់ផ្តល់នូវមតិចូលរួមណាមួយ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាម info@cchrcambodia.org ។ មួយវិញទៀត សូមទំនាក់ទំនងមក ម.ស.ម.ក តាមរយៈ ៖

ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ បឹងត្របែក ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
អ៊ីម៉ែល ៖ info@cchrcambodia.org
ទូរស័ព្ទ ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១
ទូរសារ ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០២
វ៉ែបសាយ ៖ www.cchrcambodia.org

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) គឺជាអង្គការមិនមែនរដ្ឋាភិបាល (អង្គការ) មិនចូលបក្សសម្ព័ន្ធ ឯករាជ្យដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា (កម្ពុជា)។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាព ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេស។ ម.ស.ម.ក ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយម ដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយក និងសាទរ ជាជាងព្រងើយកន្តើយ ឬជាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចឲ្យឃើញរូបសត្វ ព្រាប ស ហើរចេញពីរង្វង់មូលនៃផ្ទៃពណ៌ខៀវដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

គោលនយោបាយសង្ខេប ស្តីពី សេរីភាពបញ្ចេញមតិនៅកម្ពុជា (គោលនយោបាយសង្ខេប) គឺជាសមិទ្ធិផលនៃគម្រោងសេរីភាពបញ្ចេញមតិនៅកម្ពុជា (គម្រោង)។ គម្រោងនេះមានគោលបំណងឲ្យមានការផ្លាស់ប្តូរផ្នែកច្បាប់ ផ្នែករចនាសម្ព័ន្ធ និងគោលនយោបាយដើម្បីលើកកម្ពស់សេរីភាពបញ្ចេញមតិនៅកម្ពុជា និងត្រូវបានឧបត្ថម្ភថវិកាដោយ សហភាពអឺរ៉ុប **និង**ស្ថានទូតអង់គ្លេស។

សេចក្តីថ្លែងអំណរគុណ

គោលនយោបាយសង្ខេបនេះ អាចនឹងកើតមានទៅបានដោយសារមានការឧបត្ថម្ភថវិកាមកពី សហភាពអឺរ៉ុប **និង**ស្ថានទូតអង់គ្លេស។ មាតិកានេះគឺជាទំនួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពី ទស្សនៈរបស់សហភាពអឺរ៉ុប ឬក៏ស្ថានទូតអង់គ្លេសនោះទេ។ ម.ស.ម.ក ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួមក្នុងកិច្ចពិភាក្សាតុមូលនានា និងអ្នកដែលចូលរួមក្នុងសិក្ខាសាលាបូកសរុបកាលពីខែធ្នូ ឆ្នាំ២០១៣ ផងដែរ។

CC BY NC SA

សេចក្តីសង្ខេប

គោលនយោបាយសង្ខេបនេះ សង្ខេបលទ្ធផលនៃកិច្ចពិភាក្សាតុមូលចំនួន ៦ ដែល ម.ស.ម.ក បានរៀបចំឡើង ក្នុងរយៈពេល ២ ឆ្នាំនៃគម្រោង។ គោលនយោបាយនេះសរុបដោយមានអនុសាសន៍ផ្ទាល់ទៅដល់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា (រដ្ឋាភិបាល) ដើម្បីធ្វើឲ្យស្ថានភាពសេរីភាពបញ្ចេញមតិនៅកម្ពុជាមានភាពប្រសើរឡើង។

សិទ្ធិសេរីភាពបញ្ចេញមតិ គឺជាស្នូលនៃដំណើរការលទ្ធិប្រជាធិបតេយ្យ។ បើគ្មានសិទ្ធិក្នុងការស្វែងរក និងទទួលបាន និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង និងការចូលរួមក្នុងកិច្ចពិភាក្សានោះ ពលរដ្ឋនឹងមិនអាចចូលរួមដោយពេញលេញក្នុងជីវភាពនយោបាយជាតិរបស់ខ្លួនបានទេ។ ខណៈដែលលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមានលក្ខណៈវ័យក្មេងនៅឡើយ ស្ថានភាពសេរីភាពបញ្ចេញមតិគឺមានភាពផុយស្រួយខ្លាំងណាស់។ ព័ត៌មានថ្មីៗ និងដោយផ្ទាល់ពីបុគ្គលដែលរងផលប៉ះពាល់ ដែលសិទ្ធិសេរីភាពបញ្ចេញមតិរបស់ពួកគេត្រូវបានរឹតបន្តឹង ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ គឺមានសារៈសំខាន់ណាស់ មិនមែនតែសម្រាប់ដើម្បីបង្កើនចំណេះដឹងនោះទេ ប៉ុន្តែគឺជាឧបករណ៍ដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរ។

គម្រោងបានធ្វើការរួមជាមួយសមាជិកអង្គការមិនមែនរដ្ឋាភិបាល ក្រុមគោលដៅ និងមន្ត្រីរដ្ឋាភិបាល ដើម្បីលើកកម្ពស់ និងនាំឲ្យមានការអភិវឌ្ឍន៍ផ្នែកសេរីភាពបញ្ចេញមតិនៅកម្ពុជា។ លទ្ធផលពីកិច្ចពិភាក្សាចំនួន ៦ ដែលបានចងក្រងចេញជាគោលនយោបាយសង្ខេបនេះ ហើយរួមជាមួយនឹងកិច្ចពិភាក្សាទាំងនោះដោយផ្ទាល់ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការងាររបស់គម្រោង។ កិច្ចពិភាក្សាតុមូលបានប្រមូលផ្តុំនូវក្រុមគោលដៅផ្សេងៗជាច្រើនដូចជា អ្នកសរសេរប្លុក អ្នកប្រើប្រាស់បណ្តាញសង្គម អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងអ្នកតស៊ូមតិផ្នែកសេរីភាពបញ្ចេញមតិ ដើម្បីពិភាក្សាពីស្ថានភាពសេរីភាពបញ្ចេញមតិ ដែលក្រុមគោលដៅនីមួយៗបានរួមចំណែកនូវទស្សនៈ និងបទពិសោធន៍របស់ពួកគេផ្សេងៗពីគ្នា។[1] គោលនយោបាយសង្ខេបនេះពិភាក្សាលម្អិតពាក់ព័ន្ធនឹងប្រធានបទដែលអ្នកចូលរួមកិច្ចពិភាក្សាតុមូលនីមួយៗបានលើកឡើងក្នុងអំឡុងកិច្ចពិភាក្សាតុមូល និងត្រូវបានរួមបញ្ចូលនូវអនុសាសន៍ទាំងអស់ដែលបានផ្តល់ដោយអ្នកចូល

[1] សូមមើលឧបសម្ព័ន្ធខាងក្រោម សម្រាប់ព័ត៌មានស្តីពីកាលបរិច្ឆេទ ទីតាំង ប្រធានបទ និងអ្នកចូលរួមក្នុងកិច្ចពិភាក្សានីមួយៗ

រួម សម្រាប់ឲ្យមានភាពប្រសើរឡើងនៃស្ថានភាពសេរីភាពបញ្ចេញមតិ ពាក់ព័ន្ធនឹងការអនុវត្តន៍ការងាររបស់ពួកគេ។

អនុសាសន៍គោល ៖

អនុសាសន៍គោល ដែលទទួលបានពីកិច្ចពិភាក្សាតុមូលសម្រាប់រដ្ឋាភិបាល មានដូចខាងក្រោម ៖

- ✓ ជានាថាការតែបន្តឹងទាំងឡាយណាមកលើមាតិកានៅលើបណ្តាញអ៊ីនធើណេត ត្រូវតែជាវិធានការក្នុងករណីលើកលែងអនុលោមទៅតាមច្បាប់អន្តរជាតិដែលចែងថា (១) ការតែបន្តឹងនោះត្រូវមានចែងក្នុងច្បាប់ (២) ស្របតាមគោលបំណងមួយក្នុងគោលបំណងទាំងឡាយណាដែលមានចែងក្នុង មាត្រា ១៩ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និង (៣) ត្រូវបង្ហាញថាការធ្វើតតាំតនេះគឺចាំបាច់ ហើយត្រូវដាក់ចេញនូវវិធានការដែលតឹតតាំតធូរស្រាលបំផុត សម្រាប់ការតែបន្តឹងនេះ។
- ✓ ធ្វើសេចក្តីព្រាង និងអនុម័តច្បាប់ស្តីពីការទទួលព័ត៌មាន ដោយជានាលទ្ធភាពទទួលបានព័ត៌មានទាំងសម្រាប់អ្នកសារព័ត៌មាន និងសាធារណជន និងច្បាប់នេះគួរតែត្រូវធ្វើសេចក្តីព្រាងដោយផ្អែកលើគោលការណ៍បើកចំហអតិបរមា
- ✓ ចំពោះបទបញ្ញត្តិដែលមានលក្ខណៈមិនច្បាស់លាស់ និងរឹតបន្តឹង មានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន (ជាពិសេសស មាត្រា ១១ ១២ និង ១៤) គួរតែធ្វើសេចក្តីព្រាងសារឡើងវិញ ដើម្បីឲ្យបញ្ញត្តិទាំងនោះមានភាពច្បាស់លាស់ មានន័យប្រាកដ និងកំណត់វាក្យសព្ទច្បាស់លាស់ ដែលមិនធ្វើឲ្យងាយស្រួលក្នុងការបកស្រាយដោយបំពានច្បាប់
- ✓ លុបបទបរិហារកេរ្តិ៍ចេញពីក្រមព្រហ្មទណ្ឌ និងជានាថានឹងមិនមានការផ្តន្ទាទោសដាក់ពន្ធនាគារ សម្រាប់បទល្មើសបរិហារកេរ្តិ៍ និងបទល្មើសផ្សេងដែលពាក់ព័ន្ធ និង
- ✓ ជានាថាអាជ្ញាធរមូលដ្ឋានក្នុងគ្រប់កម្រតិទាំងអស់អនុវត្តការងារ ដោយគោរពច្បាប់ បំពេញកាតព្វកិច្ចដើម្បីបម្រើប្រជាពលរដ្ឋកម្ពុជា និងបញ្ឈប់រាល់សកម្មភាពដែលគំរាម ឬយាយីលើសកម្មជនមូលដ្ឋាន ឬប៉ុនប៉ងរារាំងប្រជាពលរដ្ឋមិនឲ្យការពារសិទ្ធិរបស់ពួកគាត់។

សេរីភាពបញ្ចេញមតិរបស់អ្នកសរសេរប្លុក

ស្វ័យពិនិច្ឆភាព (Self-censorship)

ម.ស.ម.ក បានរកឃើញថាស្វ័យពិនិច្ឆភាពក្នុងចំណោមអ្នកសរសេរប្លុកគឺជារឿងគួរឲ្យព្រួយបារម្ភជាខ្លាំង។ អ្នក ចូលរួមក្នុងកិច្ចពិភាក្សាតុមូលភាគច្រើន សារភាពថាពួកគេមានការភ័យខ្លាច នៅពេលដែលពួកគេសរសេរនៅលើអ៊ីនធើណេតដែលមានពាក់ព័ន្ធនឹងនយោបាយ រដ្ឋាភិបាល ឬអ្នកមាន។ បន្ទាប់ពីបានសរសេរអត្ថបទបែបនោះ ពួកគាត់តែងតែបារម្ភពីសុវត្ថិភាពរបស់ខ្លួន និងសុវត្ថិភាពរបស់ក្រុមគ្រួសារ។

មូលហេតុទូទៅ និងគួរឲ្យព្រួយបារម្ភបំផុត បណ្តាលឲ្យមានស្វ័យពិនិច្ឆភាព រួមមាន ភាពភ័យខ្លាចថានឹងត្រូវបានចាប់ខ្លួន ឬការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ការមិនជឿជាក់លើប្រព័ន្ធយុត្តាធិការ និងកង្វះយន្តការការពារដែលមានស្រាប់សម្រាប់អ្នកសរសេរប្លុក ។ អ្នកចូលរួមភាគច្រើនបានបង្ហាញថា ឃាតកម្មលើបុគ្គលដែលហ៊ាននិយាយស្តីឬរិះគន់លើរដ្ឋាភិបាលកាលពីអតីតកាលបានបណ្តាលឲ្យពួកគេមានភាពភ័យខ្លាច។ ចំណុចនេះបានបង្ហាញយ៉ាងច្បាស់ថា ការអនុវត្តន៍ស្វ័យពិនិច្ឆភាព បានរីករាលដាលយ៉ាងខ្លាំងនៅកម្ពុជា ហើយអ្នកសរសេរប្លុកបានសរសេរពីប្រធានបទដែលពួកគេគិតថាមិនសូវចម្រូងចម្រាស់ ដើម្បីចៀសពីបញ្ហា។ អ្នកសរសេរប្លុកជាច្រើន បានលើកឡើងផងដែរថា ពួកគេបន្តយកការសរសេរ និងមិនហ៊ាននិយាយបញ្ហាទាំងអស់ដែលពួកគេចង់ ដោយសារតែការភ័យខ្លាចការផ្តន្ទាទោស។

មិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកសរសេរប្លុក និងសូម្បីតែអ្នកអាន ក៏រួមចំណែកឲ្យមានការអនុវត្តន៍ស្វ័យ ពិនិច្ឆភាព ក្នុងចំណោមអ្នកសរសេរប្លុកមួយចំនួនផងដែរ។ អ្នកសរសេរប្លុកម្នាក់ ទទួលអ៊ីម៉ែលណែនាំពីពលរដ្ឋកម្ពុជាដែលរស់នៅបរទេស ដោយប្រាប់ថាគាត់មិនគួរសរសេរអំពីរឿងនយោបាយ ដោយសារតែ នៅកម្ពុជាមិនមានសុវត្ថិភាពគ្រប់គ្រាន់ ក្នុងការសរសេរបែបនោះទេ។ អ្នកសរសេរប្លុកមួយរូបទៀត ត្រូវបានឪពុកប្រាប់ថាគាត់នឹងកាត់ផ្តាច់សេវាអ៊ីនធើណេតរបស់នាង ប្រសិនបើនាងនៅតែបន្តសរសេររិះគន់នាយករដ្ឋមន្ត្រី ឬរដ្ឋាភិបាលនៅលើអ៊ីនធើណេត ដោយសារតែមានការភ័យខ្លាចពីសុវត្ថិភាពរបស់នាង។ អ្នកសរសេរប្លុកម្នាក់ទៀត ត្រូវបានមិត្តភក្តិដាស់តឿនឲ្យ

ប្រយ័ត្នខ្លួន បន្ទាប់ពីគាត់បានសរសេរអត្ថបទពាក់ព័ន្ធនឹងបញ្ហានយោបាយនៅលើប្លុករបស់គាត់ ហើយ ខេអាយមីឌា បានយកអត្ថបទនោះទៅផ្សាយបន្ត ។[2]

អ្នកសរសេរប្លុកមួយចំនួន និយាយថាខ្លួនអាចសរសេរ ពីស្ថានភាពនយោបាយនៅប្រទេសកម្ពុជាដោយសេរី ពេលដែលពួកគេមិនបានរស់នៅក្នុងប្រទេស។ ប៉ុន្តែ នៅពេលដែលពួកគេត្រលប់មករស់នៅក្នុងប្រទេសកម្ពុជាវិញ អារម្មណ៍ថាមានសេរីភាពត្រូវបាត់បង់។ ឧទាហរណ៍ អ្នកសរសេរប្លុកម្នាក់ហ៊ានសរសេរដោយសេរីពីស្ថានភាពសេរីភាពនយោបាយនៅកម្ពុជា ខណៈពេលដែលគាត់កំពុងសិក្សា និងរស់នៅក្នុងប្រទេសវៀតណាម ដោយសារតែគេជឿថាគ្មាននរណាអាចរកគេឃើញនោះទេ។ ប៉ុន្តែ បន្ទាប់ពីបញ្ចប់ការសិក្សា ហើយត្រលប់មកប្រទេសកម្ពុជាវិញ គេបានបន្ថយការសរសេរពាក់ព័ន្ធនឹងរឿងនយោបាយ ។

> អ្នកសរសេរប្លុកតែងតែភ័យថា ប្រសិនបើមានការចោទប្រកាន់ ឬ ផ្តន្ទាទោស គេនឹងមិនអាចទៅរកជំនួយ ពីស្ថាប័នណានោះទេ។

អ្នកចូលរួមជាទូទៅ មានអារម្មណ៍ថាអត្ថបទណាដែល មើលទៅដូចជារិះគន់ដល់អ្នកមាន និងអ្នកមានអំណាច មិនគួរផ្សព្វផ្សាយជាសាធារណៈនោះទេ។ ថ្វីបើមានការកើនឡើងយ៉ាងគំហុក នៃបណ្តាញសង្គមដូចជា ធ្វីតទ័រ និងហ្វេសប៊ុក ជាពិសេស ក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ២០១៣ អ្នកប្រើប្រាស់បណ្តាញសង្គម ជាញឹកញាប់ តែងតែមានការភ័យខ្លាចក្នុងការបញ្ចេញមតិយោបល់ពាក់ព័ន្ធនឹងបញ្ហានយោបាយ ឬរិះគន់ដល់អាជ្ញាធរពីព្រោះពួកគេខ្លាចថា ប្រសិនបើអាជ្ញាធរចោទប្រកាន់មកលើពួកគេ ពួកគេនឹងមិនអាចស្វែងរកជំនួយពីស្ថាប័នណានោះទេ។ មានករណីចំនួន ២ បានកើតឡើងក្នុងពេលថ្មីៗនេះ ដែលសាធារណជនត្រូវបានដៅមុខសញ្ញា និងគំរាមកំហែងចោទប្រកាន់ពីបទល្មើសបរិហារកេរ្តិ៍ ជាលទ្ធផលនៃការិះគន់ស្ថាប័នរដ្ឋាភិបាលនៅលើហ្វេសប៊ុក។[3]

---

[2] ខេ អាយ មីឌា ជាវែបសាយដែលផ្សាយអត្ថបទ និងព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពនយោបាយ និងសិទ្ធិមនុស្សនៅកម្ពុជា។ វែបសាយនេះល្បីឈ្មោះខាងផ្សព្វផ្សាយ «ព័ត៌មានមានលក្ខណៈរើសអំពីកម្ពុជា» និងធ្វើការគាំទ្រដល់គណបក្សប្រឆាំងដោយចំហ។ វែបសាយនេះ ត្រូវបានបិទជាច្រើនលើកច្រើនសា (សូមមើលខាងក្រោម)។ សូមចូលទៅកាន់តំណាងនេះ http://ki-media.blogspot.com/ ។

[3] ករណីដំបូងគឺ កែល ភារុណ ដែលជាគ្រូបង្រៀន ដែលត្រូវបានកោះហៅ និងគំរាមថានឹងត្រូវចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដោយសារតែរិះគន់មន្ត្រីនគរបាលនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៣។ សម្រាប់ព័ត៌មានបន្ថែម សូមអាន ម.ស.ម.ក «ករណីសិក្សា ៖

ការជាក់កំហិតលើលទ្ធភាពប្រើប្រាស់ ៖ ការទប់ស្កាត់វែបសាយ

ការទប់ស្កាត់វែបសាយ ខេអាយមីឌា ជាវែបសាយមានលក្ខណៈរិះគន់លើរដ្ឋាភិបាល ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ។ គួរកត់សម្គាល់ថាក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធើណេតមួយចំនួន ដូចជា មិត្តហ្វូន អ៊ីស៊ីខម និង អនឡាញ បានទប់ស្កាត់មិនឲ្យអ្នកអានចូលទៅកាន់វែបសាយ មិនមែនត្រឹមតែ ខេអាយមីឌា នោះទេ ប៉ុន្តែវែបសាយមួយចំនួនផ្សេងទៀត រួមមាន ខ្មែររបនីយកម្ម និង សក្រវាទី ជាវែបសាយដ៏ល្បីឈ្មោះដែលតែងតែផ្សព្វផ្សាយព័ត៌មានរិះគន់ដល់រដ្ឋាភិបាលផងដែរ។ ការទប់ស្កាត់បែបនេះកើតឡើង ដោយសារតែការលើកឡើងថាមានការណែនាំពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ប៉ុន្តែ គួរឲ្យកត់សម្គាល់ផងដែរថា ក្រុមហ៊ុនផ្តល់សេវាអ៊ីនធើណេតមួយចំនួន ដូចជា មេគង្គណិត អង្គរណិត និងសែលខាត មិនបានទប់ស្កាត់ វែបសាយទាំងនេះទេ។

អ្នកចូលរួមក្នុងកិច្ចពិភាក្សានេះជាច្រើននាក់បានសារភាពថាមាតិកា របស់ ខេអាយមីឌា មានលក្ខណៈមិនសមរម្យជាខ្លាំង ប៉ុន្តែ ពួកគេយល់ថាការទប់ស្កាត់មិនឲ្យអ្នកអានចូលទៅមើលវែបសាយបែបនេះ គឺជាការរំលោភលើសិទ្ធិសេរីភាពបញ្ចេញមតិ ទោះបីជាពួកគេមានអារម្មណ៍មិនពេញចិត្តចំពោះមាតិការបស់វែបសាយនោះក៏ដោយ។ អ្នកចូលរួមក៏បានលើកឡើងពីការព្រួយបារម្ភចំពោះវប្បធម៌នៃការទប់ស្កាត់វែបសាយ ជាពិសេសគឺថាការទប់ស្កាត់វែបសាយមួយ អាចនឹងឈានទៅរកការទប់ស្កាត់វែបសាយជាច្រើនផ្សេងទៀតដែលត្រូវបានចាត់ទុកថាប្រឆាំងនឹងរដ្ឋាភិបាល ឬសមាជិកនៃក្រុមអភិជននៅកម្ពុជា។ អ្នកចូលរួមគិតថាការសន្មត់ទុកមុនគួរតែផ្តល់ផលប្រយោជន៍ដល់វែបសាយទាំងនោះ ដើម្បីអាចចែកចាយព័ត៌មានដោយសេរី ដោយគ្មានការរឹតបន្តឹង។

លទ្ធភាពប្រើប្រាស់អ៊ីនធើណេតនៅកម្ពុជា មានការប្រមូលផ្តុំនៅក្នុងតំបន់ទីប្រជុំជន។ ជាលទ្ធផល អ្នកដែលរស់នៅក្នុងតំបន់ជនបទពុំមានលទ្ធភាពប្រើប្រាស់ ឬមានលទ្ធភាពតិចតួចដើម្បីប្រើប្រាស់ដោយសារតែហេដ្ឋារចនាសម្ព័ន្ធនៅមានកម្រិត និងនៅមានតម្លៃថ្លៃ។ អ្នកចូលរួមយល់ស្រប

តែល ការុណ» (សលាកប័ត្រព័ត៌មាន) (ខែមីនា ឆ្នាំ២០១៣) អាចអានបាន ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=54&id=5។ ករណីទី២ គឺចិត្រ សុវិជ្ជា នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ដែលត្រូវបានចាប់ខ្លួនដោយសារតែប្រកាសលើហ្វេសប៊ុកដែលមានលក្ខណៈរិះគន់មន្ត្រីនគរបាល។ រូបគេក៏ត្រូវបានគំរាមថានឹងចោទប្រកាន់ពីបទបរិហារកេរ្តិ៍ផងដែរ។ សម្រាប់ព័ត៌មានបន្ថែមសូមអាន លាង សារិទ្ធ «អ្នកប្រើប្រាស់ហ្វេសប៊ុកត្រូវបានចាប់ខ្លួនដោយសារតែប្រកាសរបស់ខ្លួន» សារព័ត៌មាន ឌឺ ភ្នំពេញ ប៉ុស្ត៍ (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣) អាចអានបាន៖ http://www.phnompenhpost.com/national/facebook-user-busted-over-posts ។

ថា គួរតែមានកិច្ចខំប្រឹងប្រែងដើម្បីបង្កើនចំនួនអ្នកប្រើប្រាស់អ៊ីនធើណេតនៅកម្ពុជា ដើម្បីអនុញ្ញាតឲ្យប្រជាពលរដ្ឋមានលទ្ធភាពប្រើប្រាស់ និងអាចបញ្ចេញមតិពួកគេនៅលើប្រព័ន្ធ អ៊ីនធើណេតបាន។

ការគ្រប់គ្រងអ៊ីនធើណេត

បច្ចុប្បន្ន មិនមានច្បាប់ណាជាក់លាក់ក្នុងការគ្រប់គ្រងអ៊ីនធើណេតនៅកម្ពុជានោះទេ ហើយមានការយល់ឃើញថាអ៊ីនធើណេតជាបណ្តាញព័ត៌មានដែលនៅសេរីជាងគេនៅកម្ពុជា។

ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ក្រសួងប្រៃសណីយ៍ បានចេញសារាចរណ៍មួយក្នុងគោលបំណងគ្រប់គ្រងការប្រើប្រាស់អ៊ីនធើណេតនៅក្នុងហាងអ៊ីនធើណេត ដែលប្រសិនបើអនុវត្តន៍តាមសារាចរណ៍មួយនេះ នឹងបណ្តាលឲ្យមានការបិទហាងអ៊ីនធើណេតស្ទើរតែទូទាំងភ្នំពេញ។[4] សេចក្តីណែនាំនេះបញ្ជាឲ្យបិទហាងការ៉ាអ៊ីនធើណេត ដែលមានទីតាំងនៅជិតសាលារៀន ឬស្ថាប័នអប់រំ ដើម្បីការពារមិនឲ្យសិស្សលេងហ្គេមតាមប្រព័ន្ធអ៊ីនធើណេត និងមើលរូបអាសអាភាស។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាតុមូលបាននិយាយថាសារាចរណ៍នេះ មិនមែនជាការស្វែងរកដំណោះស្រាយចំពោះបញ្ហានោះទេ ផ្ទុយទៅវិញ គឺបានរឹតបន្តឹងសិទ្ធិសេរីភាពប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេតសម្រាប់គោលបំណងផ្សេងទៅវិញផងដែរ។ ពួកគេក៏បានលើកឡើងផងដែរថា ជាទូទៅ ដំណើរការធ្វើសេចក្តីព្រាងច្បាប់ មានលក្ខណៈអាថ៌កំបាំង ចំណែកព័ត៌មានដែលពាក់ព័ន្ធនឹងច្បាប់ដែលកំពុងស្ថិតក្នុងការពិចារណាតែងតែមិនបានផ្សព្វផ្សាយដូនដល់សាធារណជន។

បន្ថែមពីលើនោះ មានការលើកឡើងថា មិនមានការប្រមូលយកមតិយោបល់ និងការព្រួយបារម្ភរបស់ភាគីពាក់ព័ន្ធ និងក្រុមគោលដៅ ដែលអាចនឹងរងផលប៉ះពាល់ដោយសារតែការស្នើច្បាប់នោះទេ។ "អ្នកប្រើប្រាស់អ៊ីនធើណេត" មិនមែនសំដៅត្រឹមតែអ្នកសរសេរប្លុកនោះទេ ប៉ុន្តែក៏រួមបញ្ចូលទាំងក្រុមវិស្វករផ្នែកព័ត៌មានវិទ្យា ការធ្វើពាណិជ្ជកម្មលើប្រព័ន្ធអ៊ីនធើណេត ម្ចាស់វែបសាយ និងអ្នកប្រើប្រាស់បណ្តាញសង្គម និងអ្នកប្រើប្រាស់អ៊ីនធើណេតទូទៅផងដែរ ដែលបុគ្គលទាំងនោះអាចនឹងរងផលប៉ះពាល់ពីច្បាប់នេះ ហើយដូច្នេះពួកគេគួរតែត្រូវបានផ្តល់ឱកាសឲ្យផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងច្បាប់ផងដែរ។

[4] សារាចរណ៍នេះត្រូវបានលុបចោលវិញ។ សូមអាន http://www.cambodiadaily.com/archive/telecommunications-minister-assures-internet-cafes-futures-6801/ ។

អ្នកចូលរួមខ្លះទៀតយល់ថា ការគ្រប់គ្រងអ៊ីនធើណេតអាចនឹងផ្តល់ការការពារឲ្យពួកគេបានច្រើនជាង ដោយសារតែច្បាប់នឹងកំណត់នូវវិសាលភាពនៃការគ្រប់គ្រងប្រព័ន្ធអ៊ីនធើណេត និងកំណត់នូវកាលៈទេសៈជាក់លាក់ដែលវៃបសាយអាចនឹងត្រូវបានទប់ស្កាត់។ ប៉ុន្តែ អ្នកចូលរួមទាំងនេះកត់សម្គាល់ថា នឹងអាចធ្វើបែបនេះទៅបាន លុះត្រាណាតែច្បាប់នោះមានតុល្យភាព និងត្រូវបានព្រាងដោយយោងទៅលើលក្ខខណ្ឌដ៏ជាក់លាក់បំផុតសម្រាប់តែបន្តឹងលើសេរីភាពបញ្ចេញមតិ ដែលអនុលោមតាមច្បាប់អន្តរជាតិ។ បន្ថែមពីលើនោះ ក៏មានការកត់សម្គាល់ដែរថា ប្រសិនបើច្បាប់នោះនឹងត្រូវបានព្រាងឡើង ច្បាប់នោះគួរតែ មានការពិគ្រោះយោបល់ជាមួយនឹងអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីអាចការពារសិទ្ធិសេរីភាពបញ្ចេញមតិបាន។

ផ្ទុយមកវិញ អ្នកចូលរួមខ្លះទៀតបាននិយាយថា មិនគួរមានច្បាប់គ្រប់គ្រងលើអ៊ីនធើណេតនោះទេ ដោយសារតែភ័យខ្លាចថាច្បាប់នេះនឹងត្រូវបានប្រើក្នុងវិធី ដូចនឹងសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលនឹងបង្កើតបរិយាកាសកាន់តែចង្អៀតសម្រាប់អ្នកប្រើប្រាស់អ៊ីនធើណេត ជាជាងផ្តល់ប្រយោជន៍ដល់ពួកគេ។

អនុសាសន៍៖

អង្គការសហប្រជាជាតិបានចាត់ទុកការប្រើប្រាស់អ៊ីនធើណេត ជាសិទ្ធិមនុស្សមូលដ្ឋាន។ ដើម្បីអាចបង្កើនលទ្ធភាពប្រើប្រាស់អ៊ីនធើណេត និងជានាសេរីភាពលើប្រព័ន្ធអ៊ីនធើណេត មានអនុសាសន៍មួយចំនួនដែល រដ្ឋាភិបាល គួរតែពិចារណាដូចខាងក្រោម ៖

- ✓ បង្កើតក្រុមការងារដើម្បីកំណត់គោលនយោបាយ ក្នុងការធានាថាប្រជាពលរដ្ឋកម្ពុជាអាចមានលទ្ធភាពប្រើប្រាស់អ៊ីនធើណេត ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្នែកបច្ចេកទេស និងរួមទាំងមាតិកាផងដែរ

- ✓ ដាក់ចេញគោលនយោបាយដែលអាចអនុវត្តបាន ដើម្បីបង្កើនលទ្ធភាពប្រើប្រាស់អ៊ីនធើណេតសម្រាប់ប្រជាពលរដ្ឋកម្ពុជា នៅក្នុងតំបន់ជនបទ ព្រមជាមួយនឹងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងទម្លាក់តម្លៃ

- ✓ ផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ស្តីពី ឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិជ្ជា ទៅសាធារណជន និងបង្កើតឲ្យមានការពិគ្រោះយោបល់ស្តីពីវិសាលភាព និងមាតិកាច្បាប់ និងពិចារណាយ៉ាងយកចិត្តទុកដាក់ ចំពោះសំណើទាំងឡាយណាដែលត្រូវបានធ្វើឡើង ក្នុងដំណើរការពិគ្រោះយោបល់ ឧទាហរណ៍ រដ្ឋាភិបាល គួរតែយកចិត្តទុកដាក់ចំពោះការព្រួយបារម្ភដែលបានលើកឡើងពាក់ព័ន្ធនឹង និយមន័យនៃបទល្មើសដែលត្រូវបានបង្កើតក្នុងច្បាប់ថ្មី ហើយក៏ដូចជាការដាក់ទោសមកលើបទល្មើសបែបនោះផងដែរ

- ✓ ស្វែងរកមតិយោបល់ពីភាគីពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល នៅពេលដែលធ្វើសេចក្តីព្រាងច្បាប់ទាំងឡាយណាដែលពាក់ព័ន្ធ នឹងសេរីភាពលើប្រព័ន្ធអ៊ីនធើណេត និងដាក់ឲ្យសេចក្តីព្រាងច្បាប់ទាំងនោះ សម្រាប់ការពិគ្រោះយោបល់ជាសាធារណៈ

- ✓ ធានាថាការរឹតបន្តឹងទាំងឡាយណាមកលើមាតិកានៅលើបណ្តាញអ៊ីនធើណេត ត្រូវតែជាវិធានការក្នុងករណីលើកលែងអនុលោមទៅតាមច្បាប់អន្តរជាតិដែលចែងថា (១) ការរឹតបន្តឹងនោះត្រូវមានចែងក្នុងច្បាប់ (២) ស្របតាមគោលបំណងមួយក្នុងគោលបំណងទាំងឡាយណាដែលមានចែងក្នុង មាត្រា ១៩ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និង (៣) ត្រូវបង្ហាញថាការធ្វើរឹតត្បិតនេះគឺចាំបាច់ ហើយត្រូវដាក់ចេញវិធានការដែលរឹតត្បិតធូរស្រាលបំផុត សម្រាប់ការរឹតបន្តឹងនេះ

- ✓ ធានាថាវិធានការទប់ស្កាត់វិបសាយនឹងត្រូវបានប្រើក្នុងកាលៈទេសៈដ៏ចង្អៀត និងលើកលែងបំផុត (ការសន្មត់ទុកមុនគួរតែផ្តល់ប្រយោជន៍ដល់ការរក្សាទុកវិបសាយឲ្យនៅដំណើរការ) អនុលោមតាមច្បាប់អន្តរជាតិ ដូចបាន បង្ហាញខាងលើ និងក្នុងករណីដែលមានសេចក្តីសម្រេចពីតុលាការប៉ុណ្ណោះ

- ✓ បញ្ឈប់ការទាញឲ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធើណេតទទួលខុសត្រូវ ក្នុងករណីដែលក្រុមហ៊ុននោះបដិសេធមិនព្រមទប់ស្កាត់វិបសាយ ដែលការទប់ស្កាត់នោះប៉ះពាល់ដល់សិទ្ធិបញ្ចេញមតិ ការស្នើសុំទាំងឡាយណាដែលបានដាក់ទៅក្រុមហ៊ុនផ្តល់សេវាអ៊ីនធើណេត ដើម្បីការពារមិនឲ្យចូលមើលក្នុងមាតិកាជាក់លាក់ណាមួយ គួរតែធ្វើឡើងដោយយោងតាមសេចក្តីបង្គាប់ពីតុលាការឯករាជ្យ មិននៅក្រោមឥទ្ធិពលរបស់គណបក្សនយោបាយ អង្គភាពពាណិជ្ជកម្ម ឬក៏ឥទ្ធិពលដែលមិនសមប្រកបដទៃទៀត

- ✓ បង្កើតក្រុមបច្ចេកទេសស៊ើបអង្កេត និងវិភាគទៅលើកំហុសរបស់អ្នកសរសេរប្លុក ឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ មុននឹងធ្វើការផ្តន្ទាទោស ឬសម្រេចទប់ស្កាត់វិបសាយ

- ✓ ធានាថាម្ចាស់វិបសាយដែលត្រូវបានទប់ស្កាត់ មានសិទ្ធិប្តឹងជំទាស់ចំពោះការសម្រេចចិត្តនោះ និង

- ✓ បង្កើត វេទិកាបើកចំហ ឬសមាជជាតិសម្រាប់អ្នកប្រើប្រាស់អ៊ីនធើណេតដើម្បីអនុញ្ញាតឲ្យសង្គមស៊ីវិល សកម្មជនសិទ្ធិមនុស្ស អ្នកសរសេរប្លុក បុគ្គលដែលធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយទំនើប ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធើណេត និងអ្នកសរសេរកម្មវិធី អាចពិភាក្សាពីតម្រូវការរបស់ខ្លួន និងលើកពីការព្រួយបារម្ភពាក់ព័ន្ធនឹងរដ្ឋាភិបាល។

សម្រាប់អ្នកសរសេរប្លុក៖

- ✓ ត្រូវតែសរសេរប្លុករបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងទំនួលខុសត្រូវ និងសរសេរតែអត្ថបទទាំងឡាយណាដោយប្រើព័ត៌មានច្បាស់លាស់ និងត្រឹមត្រូវ

អ្នកសារព័ត៌មាន-សេរីភាពសារព័ត៌មាន

សម្ពាធផ្នែកសេដ្ឋកិច្ច

ប្រាកបៀវត្សរ៍របស់អ្នកសារព័ត៌មាន ដែលនៅមានកម្រិតទាប នាំឲ្យកម្រិតនៃវិជ្ជាជីវៈ និងក្រមសីលធម៌ធ្លាក់ចុះ។ អ្នកសារព័ត៌មាន តែងតែទទួលសំណូកពីបុគ្គលដែលចង់លើកដង្គើង ឬការពារកេរ្តិ៍ឈ្មោះរបស់ខ្លួន ដែលបណ្តាលឲ្យសាធារណជនទូទៅ គ្មានការជឿជាក់លើសារព័ត៌មាន។

ក្នុងកិច្ចពិភាក្សាតុមូលនេះ មានការបង្ហាញយ៉ាងច្បាស់ថា សម្ពាធផ្នែកហិរញ្ញវត្ថុមកលើអ្នកសារព័ត៌មាន មានផលប៉ះពាល់យ៉ាងខ្លាំងមកលើសេរីភាពបញ្ចេញមតិ ក្នុងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី។ អ្នកសារព័ត៌មានតែងតែទទួលបានប្រាក់បៀវត្សទាប ជាលទ្ធផលធ្វើឲ្យខ្វះខាតវិជ្ជាជីវៈ និងអនុវត្តក្រមសីលធម៌បែបធូរលុង ជាពិសេស បុគ្គលដែលធ្វើការនៅក្នុងអង្គភាពសារព័ត៌មានក្នុងស្រុក/ជាតិ។ ប្រាក់បៀវត្សដែលនៅមានកម្រិតទាប តែងតែបណ្តាលឲ្យអ្នកសារព័ត៌មានទាំងនោះទទួលយកសំណូក ពីបុគ្គលដែលមានបំណងចង់លើកកម្ពស់ ឬការពារកេរ្តិ៍ឈ្មោះរបស់ខ្លួន។ នេះនាំឲ្យមានភាពភ័យខ្លាចថា ការទទួលយកសំណូកនឹងបណ្តាលឲ្យសាធារណជនខ្វះជំនឿទៅលើសារព័ត៌មាន និងអ្នកយកព័ត៌មាន។ ជាលទ្ធផល សាធារណជននឹងស្ទាក់ស្ទើរក្នុងការនិយាយជាមួយសារព័ត៌មាន ដែលនឹងកាន់តែតឹតបន្តឹងសេរីភាពបញ្ចេញមតិ។ គួរឲ្យកត់សម្គាល់ផងដែរថា កម្រិតនៃការដាក់ពិន័យជាប្រាក់ដែលមានចែងក្នុងច្បាប់ស្តីពី របបសារព័ត៌មាន ឆ្នាំ១៩៩៥ ក៏ហាក់ដូចជាមានកម្រិតខ្ពស់ បើប្រៀបធៀបមកប្រាក់ខែរបស់អ្នកសារព័ត៌មាន។

ចំពោះអង្គភាពសារព័ត៌មាន សម្ពាធផ្នែកហិរញ្ញវត្ថុក៏ជាបញ្ហាមួយយ៉ាងធំផងដែរ។ អ្នកចូលរួមជាច្រើនបានពន្យល់ពីរបៀបដែលភ្នាក់ងារសារព័ត៌មានធំៗ និងមានអំណាចមួយចំនួនតូច បានគាបសង្កត់ការប្រកួតប្រជែង។ ពួកគេពន្យល់ថាភ្នាក់ងារសារព័ត៌មានពឹងផ្អែកលើការផ្សាយពាណិជ្ជកម្ម ដើម្បីប្រាក់ចំណេញ។ យោងតាមការរៀបរាប់របស់អ្នកចូលរួម ម្ចាស់ពាណិជ្ជកម្មភាគច្រើន មានបំណងផ្សព្វផ្សាយពាណិជ្ជកម្មនៅលើបណ្តាញទូរទស្សន៍ធំៗមួយចំនួនតូចប៉ុណ្ណោះ ដែលការធ្វើបែបនេះធ្វើឲ្យភ្នាក់ងារព័ត៌មានឯករាជ្យ តែមានទំហំតូចត្រូវខ្ជោតចេញពីទីផ្សារ។ ភ្នាក់ងារសារព័ត៌មានដ៏មានឥទ្ធិពលទាំងនេះ អាចពង្រីកខ្លួនយ៉ាងឆាប់រហ័សដោយសារតែកង្វះវិធានការគ្រប់គ្រង ពហុកម្ម

សិទ្ធិ និងកម្មសិទ្ធិរបស់រដ្ឋដោយផ្ទាល់។ ចំណុចនេះធ្វើឲ្យអ្នកមាន និងអ្នកមានអំណាចអាចកាន់កាប់អង្គភាពព័ត៌មានបានជាច្រើន ដែលរួមមាន សារព័ត៌មានគ្រប់ប្រភេទ ដូចជា សារព័ត៌មានបោះពុម្ព ទូរទស្សន៍ និងវិទ្យុ។ ចំណុចនេះក៏អនុញ្ញាតឲ្យសារព័ត៌មានមួយផ្នែកធំនៅកម្ពុជា ត្រូវបានគ្រប់គ្រងដោយសមាជិកនៃគណបក្សកាន់អំណាចផងដែរ។ បញ្ហាមួយវិញទៀត ការធ្វើបែបនេះអាចនឹងឈានដល់ការកាន់កាប់ផ្តាច់មុខផ្នែកនយោបាយ និងទស្សនៈ ក្នុងការគ្របដណ្តប់លើស្ថានភាពសារព័ត៌មានទាំងមូល ដែលជាការរឹតបន្តឹងយ៉ាងខ្លាំងមកលើសេរីភាពបញ្ចេញមតិ។

> វិបត្តិហិរញ្ញវត្ថុរបស់ភ្នាក់ងារសារព័ត៌មាន អាចមានន័យថា ការបម្រើប្រយោជន៍សាធារណៈ និងសេរីភាពបញ្ចេញមតិ គឺជាចំណុចបន្ទាប់បន្សំ ជាងការទទួលបានការផ្សាយពាណិជ្ជកម្មពីក្រុមហ៊ុនឯកជន។

មានការបញ្ជាក់ដែរថា ប្រសិន បើភ្នាក់ងារសារព័ត៌មាន ត្រូវបានមើលឃើញថាគាំទ្រគណបក្សប្រឆាំង នោះភ្នាក់ងារសារព័ត៌មានទាំងនោះ នឹងបាត់បង់ កិច្ចសន្យាការផ្សាយពាណិជ្ជកម្មរបស់ពួកគេ ឬក៏ធ្វើឲ្យម្ចាស់ពាណិជ្ជកម្មធំៗ មិនសូវហ៊ានផ្សាយពាណិជ្ជកម្មជាមួយភ្នាក់ងារសារព័ត៌មានទាំងនោះ។ ចំណុចនេះដោយសារតែម្ចាស់ពាណិជ្ជកម្មដែលផ្សាយពាណិជ្ជកម្ម មិនចង់ឲ្យគេឃើញថាជាអ្នកប្រឆាំងរដ្ឋាភិបាល។

អ្នកចូលរួមមួយចំនួនក៏បានបង្ហាញពីការព្រួយបារម្ភថា សម្ពាធផ្នែកហិរញ្ញវត្ថុ ដែលមានមកលើភ្នាក់ងារ និងអង្គភាពសារព័ត៌មានអាចនឹងប៉ះពាល់ដល់គុណភាពការងារ។ ពួកគេក៏បានលើកឡើងថា ការងាររបស់អ្នកសារព័ត៌មានក៏ត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់ទទួលបានកិច្ចសន្យាផ្សាយពាណិជ្ជកម្ម ដើម្បីធានាថាមានការផ្សព្វផ្សាយពីរឿងល្អៗរបស់អង្គភាពជាក់លាក់មួយចំនួន ដើម្បីអាចទទួលបានប្រាក់ចំណូល។ សេរីភាពបញ្ចេញមតិ និងការបម្រើផលប្រយោជន៍សាធារណៈជាការអាទិភាពបន្ទាប់។

ការបង្កើនសមត្ថភាព

ប្រទេសកម្ពុជា មានសាលាតែមួយប៉ុណ្ណោះដែលផ្តល់ចំណេះដឹងផ្នែកវិជ្ជាជីវៈសារព័ត៌មានជាផ្លូវការ គឺដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ កង្វះខាតការអប់រំផ្នែកវិជ្ជាជីវៈសារព័ត៌មាន បណ្តាលឲ្យមានការខ្វះខាតវិជ្ជាជីវៈក្នុងឧស្សាហកម្មនេះ។

ចំណុចនេះក៏មានន័យថាអ្នកសារព័ត៌មានជាច្រើន ក៏មិនសូវទទួលបានការបណ្តុះបណ្តាល និងជំនាញដែលចាំបាច់ក្នុងការអនុវត្តន៍ការងាររបស់ពួកគេឲ្យមានប្រសិទ្ធភាពផងដែរ។ បញ្ហានេះ រួមផ្សំនឹងការស្ទាក់ស្ទើររបស់ភ្នាក់ងារសារព័ត៌មានក្នុងការដាក់ទុន ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពសម្រាប់បុគ្គលិករបស់ខ្លួន។ អ្នកចូលរួមជាច្រើនយល់ស្របថាស្ថាប័នសារព័ត៌មានតែងតែបដិសេធមិនបញ្ជូនបុគ្គលិកដើម្បីឲ្យទៅទទួលការអប់រំជំនាញបន្ថែម។ បញ្ហាទាំង ២ នេះបង្កឲ្យបទដ្ឋាននៃការផ្សព្វផ្សាយព័ត៌មាននៅមានគុណភាពអន់ខ្សោយ។

លទ្ធភាពទទួលព័ត៌មាន

អ្នកចូលរួមជាច្រើនបានលើកឡើងថា លទ្ធភាពស្វែងរកព័ត៌មានអំពីរដ្ឋាភិបាល បានអភិវឌ្ឍយ៉ាងខ្លាំងក្នុងរយៈពេល ១០ ទៅ ១៥ឆ្នាំ កន្លងមកនេះ។ កាលពីអតីតកាល អ្នកសារព័ត៌មានតែងតែប្រឈមនឹងផលលំបាក នៅពេលដែលស្នើសុំព័ត៌មានពីមន្ត្រីរដ្ឋាភិបាល និងតែងតែជួបនឹងភាសាដែលមានលក្ខណៈប្រមាថភាតទាន និងអាកប្បកិរិយាបែបគំរាមកំហែង។ មានអ្នកចូលរួមជាច្រើនបានលើកឡើងថា មន្ត្រីរដ្ឋាភិបាលបច្ចុប្បន្នមានការគោរពចំពោះអ្នកសារព័ត៌មានច្រើនជាងមុន និងតែងតែបដិសេធដោយអាកប្បកិរិយាសុភាព ក្នុងករណីដែលពួកគេមិនចង់ឆ្លើយសំណួរណាមួយ។ អ្នកចូលរួមបានរាយការណ៍ថា ការអភិវឌ្ឍន៍ផ្នែកវែបសាយរបស់រដ្ឋាភិបាលក៏បានជួយសម្រួលដល់លទ្ធភាពទទួលព័ត៌មានរបស់អ្នកសារព័ត៌មានផងដែរ។

ថ្វីបើយ៉ាងនេះក៏ដោយ សិទ្ធិក្នុងការទទួលបានព័ត៌មាននៅមិនទាន់បានធានាដោយច្បាប់ និងត្រូវបានរាយការណ៍ថាអ្នកសារព័ត៌មានជាច្រើនជួបប្រទះនឹងការលំបាក ក្នុងការស្វែងរកឯកសាររបស់រដ្ឋាភិបាល ឬសុំសម្រង់សម្តីរបស់មន្ត្រីសាធារណៈ។ អ្នកចូលរួមបានប្រាប់ពីករណីដែលមន្ត្រីរដ្ឋាភិបាល អនុញ្ញាតឲ្យតែអ្នកសារព័ត៌មានមកពីអង្គភាពជាក់លាក់មួយចំនួនដើម្បីអាចចូលរួមក្នុងកម្មវិធីខ្លះដែលរៀបចំដោយរដ្ឋាភិបាល ដូចជា សន្និសីទសារព័ត៌មានជាដើម។

បច្ចុប្បន្នក្រសួង និងស្ថាប័នរដ្ឋមួយចំនួនបានតែងតាំងអ្នកនាំពាក្យពិសេស ដើម្បីឆ្លើយតបនឹងសំណួរ និងសំណើសុំព័ត៌មានពីអ្នកសារព័ត៌មាន។ អង្គការសង្គមស៊ីវិលមួយចំនួន រួមទាំង ក្លឹបអ្នកកាសែតកម្ពុជា ក៏បានរួមចំណែកក្នុងការជំរុញឲ្យក្រសួង ដើម្បីតែងតាំងអ្នកនាំពាក្យ និងផ្តល់ការបណ្តុះបណ្តាល និងព័ត៌មានគ្រប់គ្រាន់ដល់អ្នកនាំពាក្យទាំងនោះផងដែរ។ នេះជាការវិវឌ្ឍន៍មួយគួរឲ្យកត់សម្គាល់ ដោយសារតែក្រសួងរដ្ឋាភិបាលមួយចំនួនបានបញ្ជូនមន្ត្រីផ្នែកសារព័ត៌មានដើម្បីចូល

រួមវគ្គបណ្តុះបណ្តាល របស់ក្លឹបអ្នកកាសែតកម្ពុជា ឬក្រសួងព័ត៌មាន។ ខណៈពេលដែលនេះគឺជាចំណុចគួរឲ្យកោតសរសើរ នៅមានក្រសួងមួយចំនួនដែលស្ទាក់ស្ទើរក្នុងការតែងតាំងអ្នកនាំពាក្យ។ បន្ថែមពីលើនោះ អ្នកនាំពាក្យមួយនៃក្រសួងមួយចំនួនមិនទទួលបានការបណ្តុះបណ្តាល និងព័ត៌មានគ្រប់គ្រាន់ ហើយព័ត៌មានផ្តល់ទៅអ្នកសារព័ត៌មានតែងតែមិនច្បាស់លាស់ ឬមិនត្រឹមត្រូវ។

អ្នកចូលរួមមួយចំនួន បានបញ្ចេញមតិយោបល់ពីកង្វះការសហការណ៍រវាងស្ថាប័នរដ្ឋាភិបាល និងអ្នកសារព័ត៌មាន។ អ្នកចូលរួមភាគច្រើនរៀបរាប់ថា មន្ត្រីរដ្ឋាភិបាលតែងតែមានការយឺតយ៉ាវ ក្នុងការឆ្លើយតបចំពោះសំណួររបស់អ្នកសារព័ត៌មាន។ ក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ ១៩៩៥ មាត្រា ៥ ចែងថា មន្ត្រីរដ្ឋាភិបាលមានរយៈពេល ៣០ថ្ងៃ ក្នុងការឆ្លើយតបទៅនឹងសំណើជាលាយលក្ខណ៍អក្សររបស់អ្នកសារព័ត៌មាន។ រយៈពេល ៣០ ថ្ងៃនេះ ហាក់ដូចជាយូរពេក និងមិនអាចអនុវត្តទៅបាននោះទេសម្រាប់អ្នកសារព័ត៌មានដែលត្រូវផ្សព្វផ្សាយព័ត៌មានជារៀងរាល់ថ្ងៃ។ ប៉ុន្តែទោះបីជាមិនមានការកំណត់ រយៈពេល ៣០ ថ្ងៃនេះ អ្នកចូលរួមជាច្រើនជឿថារដ្ឋាភិបាលតែងតែងលាក់ទុកព័ត៌មានដែលរដ្ឋាភិបាលគិតថាជាព័ត៌មានរសើប ឬក៏អាចណ្តាលឲ្យមានផលប៉ះពាល់ដល់ប្រយោជន៍របស់ក្រុមខ្លួន។

សុវត្ថិភាពអ្នកសារព័ត៌មាន

អ្នកចូលរួមបានបង្ហាញយ៉ាងច្បាស់ថា ពួកគេមិនហ៊ានសរសេរដោយសេរីពីអ្វីដែលពាក់ព័ន្ធនឹងរដ្ឋាភិបាល ឬបុគ្គលដែលពាក់ព័ន្ធ នឹងរដ្ឋាភិបាល ដោយសារតែការភ័យខ្លាចថានឹងមានការយាយី ការគំរាមកំហែង និងអំពើហិង្សា។ អ្នកចូលរួមមួយរូប បានលើកឡើងថារូបលោកទទួលបានការគំរាមសម្លាប់រាប់រយដងក្នុងរយៈពេល ២០ឆ្នាំ ក្នុងអាជីពជាអ្នកសារព័ត៌មាន។ ជាលទ្ធផល មានការរាយការណ៍ថា ស្វ័យពិរុទ្ធភាពនៅក្នុងចំណោមអ្នកសារព័ត៌មាន ក៏កើនឡើងផងដែរ។

> អ្នកសារព័ត៌មាន ធ្វើការក្នុងភ្នាក់ងារសារព័ត៌មានជាតិ តែងតែមានអារម្មណ៍ថាខ្លួនមិនត្រូវបានគេការពារ។

អ្វីដែលបង្ហាញយ៉ាងច្បាស់នោះ គឺថាអ្នកសារព័ត៌មានដែលធ្វើការឲ្យភ្នាក់ងារសារព័ត៌មានជាតិ តែងតែមានអារម្មណ៍គ្មានសុវត្ថិភាព នៅពេលដែលពួកគេធ្វើការ ជាងអ្នកធ្វើការនៅក្នុងភ្នាក់ងារសារព័ត៌មានបរទេស ដោយពួកគេមានអារម្មណ៍ថានៅទីនោះ មានធនធានគ្រប់គ្រាន់សម្រាប់ជួយដល់បុគ្គលិក ពេលដែលពួកគេប្រឈមមុខនឹងបញ្ហា ឬក៏ត្រូវបានគំរាមកំហែង។

ក្រមខណ្ឌច្បាប់

អ្នកចូលរួមជាទូទៅបានឲ្យដឹងថា សិទ្ធិសេរីភាពបញ្ចេញមតិរបស់ខ្លួនត្រូវបានធានាក្នុងមាត្រា ៤១ នៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) ប៉ុន្តែពួកគេមិនមានលទ្ធភាពទទួលបានសិទ្ធិទាំងនេះក្នុងការអនុវត្តន៍ជាក់ស្តែងនោះទេ។

អ្នកចូលរួមជាច្រើនលើកឡើងពីការព្រួយបារម្ភពីការប្រើប្រាស់សកម្មភាពផ្នែកច្បាប់ជាញឹកញាប់ មកលើអ្នកសារព័ត៌មាន ពីបទបរិហារកេរ្តិ៍ បទផ្តល់ព័ត៌មានមិនពិត និងជ្រៀតជ្រែកជីវភាពឯកជនរបស់អ្នកដទៃ។ ពួកគេក៏បានលើកពីការព្រួយបារម្ភថាតុលាការតែងតែកាត់ទោសអ្នកសារព័ត៌មាន ដោយប្រើប្រាស់ក្រមព្រហ្មទណ្ឌជាជាងច្បាប់ស្តីពីរបបសារព័ត៌មាន។

អនុសាសន៍

រដ្ឋាភិបាលគួរតែ៖

- ✓ ធ្វើសេចក្តីព្រាង និងអនុម័តច្បាប់ស្តីពីការទទួលព័ត៌មាន ដោយធានាលទ្ធភាពទទួលបានព័ត៌មានទាំងសម្រាប់អ្នកសារព័ត៌មាន និងសាធារណជន និងច្បាប់នេះគួរតែត្រូវធ្វើសេចក្តីព្រាងដោយផ្អែកលើគោលការណ៍បើកចំហអតិបរមា
- ✓ ពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញផ្នែកសារព័ត៌មាន និងអង្គការសង្គមស៊ីវិល នៅពេលធ្វើសេចក្តីព្រាងច្បាប់ ដើម្បីធានាថាច្បាប់នោះមានតុល្យភាព និងមានប្រសិទ្ធភាព
- ✓ ពិនិត្យមើលបទបញ្ញត្តិដាក់ពិន័យក្នុងច្បាប់ស្តីពីរបបសារព័ត៌មានសាជាថ្មី និងបន្ទាបតម្លៃនៃការបង់ប្រាក់ពិន័យ
- ✓ ចំពោះបទបញ្ញត្តិដែលមានលក្ខណៈមិនច្បាស់លាស់ និងរឹតបន្តឹង មានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន (ជាពិសេសស មាត្រា ១១ ១២ និង ១៤) គួរតែធ្វើសេចក្តីព្រាងសាឡើងវិញ ដើម្បីឲ្យបញ្ញត្តិទាំងនោះមានភាពច្បាស់លាស់ មានន័យប្រាកដ និងកំណត់វាក្យសព្ទច្បាស់លាស់ ដែលមិនធ្វើឲ្យងាយស្រួលក្នុងការបកស្រាយដោយបំពានច្បាប់
- ✓ លុបបទបរិហារកេរ្តិ៍ចេញពីក្រមព្រហ្មទណ្ឌ និងធានាថានឹងមិនមានការផ្តន្ទាទោសដាក់ពន្ធនាគារ សម្រាប់បទល្មើសបរិហារកេរ្តិ៍ និងបទល្មើសផ្សេងដែលពាក់ព័ន្ធ
- ✓ បង្កើតស្ថាប័នរដ្ឋ និងឯកជន ដើម្បីផ្តល់ការអប់រំផ្នែកវិជ្ជាជីវៈសារព័ត៌មាន ទៅដល់បុគ្គលិកផ្នែកសារព័ត៌មាន
- ✓ ផ្តល់ឱកាសទទួលបានអាហារូបករណ៍ដល់សិស្សផ្នែកសារព័ត៌មានឲ្យបានចាប់ពី ២០០ ទៅ ៣០០ នាក់ក្នុងមួយឆ្នាំ
- ✓ ធានាថាប្រព័ន្ធតុលាការនឹងប្រើប្រាស់ច្បាប់ស្តីពីរបបសារព័ត៌មានចំពោះករណីពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ជាជាងប្រើប្រាស់ក្រមព្រហ្មទណ្ឌ
- ✓ ធានាថា ស្ថាប័នរដ្ឋ និងក្រសួងនីមួយៗ មានអ្នកនាំពាក្យដែលទទួលបានការបណ្តុះបណ្តាល

និងបានដឹងព័ត៌មានគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងសំណួរពីអ្នកសារព័ត៌មាន និងសាធារណជន

- ✓ ជំរុញឲ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បង្កើតស្ថានីយថ្មី និងពង្រីកការផ្សាយរបស់ដល់តំបន់ជនបទដាច់ស្រយាល
- ✓ បញ្ឈប់ការជ្រៀតជ្រែកលើមាតិការបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និង
- ✓ ពិនិត្យ និងជំរុញឲ្យមានការផ្លាស់ប្តូរយ៉ាងសមរម្យសម្រាប់ប្រាក់បៀវត្សរបស់អ្នកយកព័ត៌មាន ជាពិសេស ប្រាក់ខែគោលសម្រាប់អ្នកសារព័ត៌មាន។

សហគមន៍អ្នកសារព័ត៌មាននៅកម្ពុជាគួរតែ ៖

- ✓ បង្កើតក្រមសីលធម៌អ្នកសារព័ត៌មាន/អ្នកយកព័ត៌មាន/ក្លាក់ងារសារព័ត៌មានរួមមួយ ដើម្បីអាចធ្វើជាការណែនាំដល់ការងាររបស់ពួកគេ និងដើម្បីធានាឲ្យមានបទដ្ឋានកម្រិតខ្ពស់សម្រាប់សារព័ត៌មាននៅកម្ពុជា
- ✓ ប្រឹងឲ្យអស់ពីលទ្ធភាពក្នុងការការពារអ្នកសារព័ត៌មាន ពីការចោទប្រកាន់តាមអំពើចិត្តពីបទបរិហារកេរ្តិ៍ និងបទផ្តល់ព័ត៌មានមិនពិត និង
- ✓ បង្កើនសមត្ថភាពសម្រាប់អ្នកសារព័ត៌មាន និងពង្រឹងវិជ្ជាជីវៈតាមរយៈការបង្កើនប្រាក់ឈ្នួលផ្តល់ការបណ្តុះបណ្តាលឲ្យបានល្អជាងនេះ និងផ្តោតលើការរាយការណ៍ដោយមានទំនួលខុសត្រូវ។

អ្នកតស៊ូមតិខាងសេរីភាពបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស និងសកម្មជន

តំណាងសហគមន៍ និងអ្នកការពារសិទ្ធិមនុស្ស

អ្នកចូលរួមជាច្រើនបានលើកឡើងពីការប្រើប្រាស់អំពើហិង្សាជាញឹកញាប់ ពីអាជ្ញាធរដើម្បីគាបសង្កត់មកលើការរៀបចំបាតុកម្ម និងការបង្ក្រាបមកលើការធ្វើបាតុកម្មដោយសន្តិវិធី។ យុវជនដែលមាននិន្នាការនយោបាយឯករាជ្យ បានពន្យល់ថាពួកគេតែងតែត្រូវបានគំរាម និងរឹតបន្តឹងមិនឲ្យចូលរួមក្នុងសកម្មនិយមនយោបាយ ទាំងក្នុង និងក្រៅរបងសាកលវិទ្យាល័យ។ អ្នកចូលរួមបានយល់ស្របគ្នាថា ទូរទស្សន៍ វិទ្យុ និងសារព័ត៌មានភាគច្រើនរាយការណ៍ព័ត៌មានដែលគ្មានគុណភាព ហើយតែងតែមានអារម្មណ៍ថា ភ្នាក់ងារសារព័ត៌មានភាគច្រើនបង្ហាញតែសកម្មភាពជារង្វៀនរបស់រដ្ឋាភិបាល។

អ្នកចូលរួមបានលើកពីការព្រួយបារម្ភ ថាសហជីព និងអង្គការមួយចំនួនត្រូវបានហាមឃាត់មិនឲ្យចុះឈ្មោះដោយស្របច្បាប់ ដែលនេះរឹតបន្តឹងមកលើសកម្មភាពរបស់ពួកគេ។ អ្នកចូលរួមបានយល់ស្របគ្នាជាទូទៅថា ប្រព័ន្ធយុត្តាធិការ មិនឯករាជ្យ ហើយតែងតែត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយដើម្បីគំរាម និងសម្លុតសកម្មជនជីធ្លី សមាជិកសហជីព និងសហគមន៍ដទៃទៀត។

មេធាវី

អ្នកចូលរួមបានយល់ស្របថា អ្នកជំនាញខាងច្បាប់ជាច្រើន តែងប្រឈមនឹងការរឹតត្បិតលើសេរីភាពបញ្ចេញមតិ។ ឧទាហរណ៍ នៅពេលដែលមេធាវីព្យាយាមផ្សព្វផ្សាយការវិភាគផ្នែកច្បាប់លើករណីរឿងក្តីរបស់ខ្លួន តាមរយៈប្រព័ន្ធសារព័ត៌មាន ដើម្បីអំពាវនាវឲ្យមានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់កូនក្តីរបស់ខ្លួន នោះពួកគាត់នឹងត្រូវបានគេគំរាមកំហែង និងសម្លុត។ ករណីជាច្រើនបង្ហាញឲ្យដឹងថា ប្រសិនណាមេធាវីជាតំណាងឲ្យកូនក្តីដែលត្រូវបានគេចោទប្រកាន់ថាបានប្រឆាំងនឹងរដ្ឋាភិបាល មេធាវីនោះក៏នឹងត្រូវបានគេដៅមុខផងដែរ។

មតិស្របជាច្រើនបានយល់ថា មេធាវីខាងសិទ្ធិមនុស្សបានប្រឈមបញ្ហាជាច្រើន ក្នុងពេលបំពេញការកិច្ចរបស់ខ្លួន។ បញ្ហាទាំងនេះ រាប់បញ្ចូលទាំងការពន្យារពេល និងការបង្អាក់ដំណើរការ

នៅពេលដែលព្យាយាមស្វែងរកសំណុំរឿងក្តីពីព្រះរាជអាជ្ញា មុនពេលដែលអាចធ្វើការសាកសួរកូនក្តី។ មេធាវីជាច្រើនតែងត្រូវបានគេមិនអនុញ្ញាតិឲ្យត្រួតពិនិត្យកស្តុតាងដាក់បន្ទុក មុនពេលត្រូវបាននាំទៅកាន់សវនាការ។ ពួកគាត់ក៏មានអារម្មណ៍ថា ត្រូវបានគេរឹតត្បិតដោយមិនមានមូលដ្ឋាន មិនឲ្យផ្សព្វផ្សាយករណីរឿងក្តីរបស់ខ្លួនតាមប្រព័ន្ធសារព័ត៌មាន ហើយក៏មិនអាចផ្សព្វផ្សាយពីយោបល់ ឬការវិភាគរបស់ខ្លួនពាក់ព័ន្ធនឹងករណីច្បាប់និងបទបញ្ញត្តិ ឬសាលក្រមតុលាការជាដើម។[5] សមាជិកម្នាក់នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានវត្តមានក្នុងកិច្ចពិភាក្សារវាងសង្គមស៊ីវិលនិងរដ្ឋាភិបាល កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២[6] បានឆ្លើយតបថា ប្រសិនណាមានកស្តុតាងបង្ហាញថា ចៅក្រមបានរារាំងមេធាវីក្នុងការទទួលបានឯកសារពីតុលាការនោះ គណៈមេធាវីស្វាគមន៍ឲ្យដាក់ពាក្យបណ្តឹងមកស្ថាប័ននេះ ដើម្បីឲ្យគណៈមេធាវីអាចចាត់វិធានការបន្ទាប់លើករណីនោះ។

អ្នកចូលរួមជាច្រើន បានពន្យល់ថា មេធាវីជាញឹកញាយមានការភ័យខ្លាចក្នុងការការពារក្តីដែលពាក់ព័ន្ធ នឹងរឿងនយោបាយ ជាពិសេសករណីសិទ្ធិដីធ្លី ដែលជាប់ពាក់ព័ន្ធនឹងអ្នកមានអំណាច។ មេធាវីជាច្រើនត្រូវប្រឈមមុខនឹងបទចោទប្រកាន់ព្រហ្មទណ្ឌ ឧទាហរណ៍ នៅពេលតំណាងឲ្យសហគមន៍ដែលរងផលប៉ះពាល់ដោយសារការបំពានសិទ្ធិដីធ្លី ដែលក្នុងនោះមេធាវីជាច្រើនត្រូវបានចោទពីបទញុះញង់ជាដើម។

---

[5] កាលពីមុន នៅក្នុងមាត្រា ១៥ នៃក្រមសីលធម៌របស់មេធាវី «គ្រប់អន្តរាគមន៍ជាសាធារណៈ ឬតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាសាធារណៈរបស់មេធាវី ក្នុងឋានៈខ្លួនជាមេធាវី អាចអនុញ្ញាតិឲ្យធ្វើបានតែក្នុងក្របខណ្ឌនៃការគោរពដោយម៉ឺងម៉ាត់នូវកាតព្វកិច្ចនៃវិជ្ជាជីវៈ។ អន្តរាគមន៍បែបនេះ ទាមទារឲ្យមានការប្រុងប្រយ័ត្ន។ ត្រូវមានការផ្តល់ជាព័ត៌មាន និងប្រឹក្សាជាមុនជាមួយប្រធានលើកលែងតែមិនអាចធ្វើទៅបាន។» ប៉ុន្តែ ចំណុចនេះត្រូវបានធ្វើវិសោធនកម្ម ក្នុង ឆ្នាំ ២០១២ ហើយបច្ចុប្បន្នមាត្រា ១៧ ថ្មី មិនតម្រូវឲ្យមេធាវីសុំការអនុញ្ញាតមុនពេលនឹងនិយាយជាមួយអ្នកសារព័ត៌មានទៀតនោះទេ ប៉ុន្តែគ្រាន់តែឲ្យគោរពកាតព្វកិច្ចនៃវិជ្ជាជីវៈ។ ទោះជាយ៉ាងណាក៏ដោយ គណៈមេធាវីបានធ្វើលិខិតមួយទៅសមាជិករបស់ខ្លួន នាថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ដោយអះអាងថាគណៈមេធាវីនឹងចាត់វិធានការផ្លូវច្បាប់ មកលើមេធាវីណាដែលធ្វើឲ្យខូចខាតដល់កេរ្តិ៍ឈ្មោះគណៈមេធាវី តាមរយៈការចែកចាយព័ត៌មានជាសាធារណៈ។ សម្រាប់ព័ត៌មានបន្ថែម សូមអានសេចក្តីថ្លែងការណ៍រួមរបស់ ម.ស.ម.ក «គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវតែឈប់ជ្រៀតជ្រែកមកលើមេធាវី» (ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣)
<http://www.cchrcambodia.org/media/files/press_release/358_jsobmiwtl02_en.pdf> មាត្រាចំនួន២ ដែលហាក់ដូចជាមានលក្ខណៈរឹតបន្តឹងស្តីពីការផ្តល់មតិមកលើសេចក្តីសម្រេចរបស់តុលាការរួមមាន មាត្រា ៥២២ និងមាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ។

[6] កិច្ចពិភាក្សានេះត្រូវបានម.ស.ម.ករៀបចំធ្វើឡើងនៅសណ្ឋាគារអ៊ីមភីរៀល ដើម្បីប្រមូលមតិឆ្លើយតប ដែលប្រមូលបានពីកិច្ចពិភាក្សាតុមូល ក្នុងគោលបំណងបញ្ចុះបញ្ចូលជាមតិជាមួយតំណាងរដ្ឋាភិបាល។

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល

អ្នកចូលរួមជាច្រើនបានលើកឡើងថា ការងាររបស់ពួកគាត់ត្រូវបានរឹតត្បិត និងរារាំងជាបន្តបន្ទាប់ ពីសំណាក់អាជ្ញាធរមូលដ្ឋាន ជាពិសេសនៅពេលដែលរៀបចំវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ដល់សហគមន៍។

អនុសាសន៍

រដ្ឋាភិបាលគួរតែ៖

- ✓ បញ្ឈប់ការតាមដាន និងតែបន្តឹងលើសកម្មភាពរបស់សកម្មជនការពារសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាល
- ✓ ឈប់ប្រើប្រាស់ប្រព័ន្ធតុលាការ ជាមធ្យោបាយក្នុងការគំរាមកំហែង និងសម្ភុតសកម្មជនការពារសិទ្ធិមនុស្ស
- ✓ ធានាថា អាជ្ញាធរមូលដ្ឋាននៅគ្រប់កម្រិតទាំងអស់អនុវត្តការងាររបស់ខ្លួនអនុលោមតាមច្បាប់ បំពេញការកិច្ចរបស់ខ្លួនក្នុងការបម្រើពលរដ្ឋ និងបញ្ឈប់រាល់សកម្មភាពដែលសម្ភុតគំរាម ឬយាយីសកម្មជនសហគមន៍ ឬមានបំណងរារាំងពួកគាត់ពីការដែលអាចការពារសិទ្ធិរបស់ខ្លួនបាន
- ✓ ពង្រឹងការអនុវត្តក្រមសីលធម៌ និងយន្តការទំនួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច និងផ្តន្ទាទោសចំពោះបុគ្គលណាដែលរំលោភបំពានលើសិទ្ធិបញ្ចេញមតិ និង
- ✓ ផ្តល់ការអប់រំបណ្តុះបណ្តាលដល់អាជ្ញាធរសាធារណៈស្តីពីសិទ្ធិមនុស្ស និងសិទ្ធិក្នុងការបញ្ចេញមតិ។

តុលាការគួរតែ៖

- ✓ ដើរតួយ៉ាងឯករាជ្យ និងអនុលោមតាមបទដ្ឋានអន្តរជាតិក្នុងការជំនុំជម្រះក្តីដោយយុត្តិធម៌ និងគោលការណ៍ច្បាប់ និង
- ✓ ធានាបកស្រាយច្បាប់ឲ្យបានត្រឹមត្រូវ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

តួអង្គដទៃទៀត និងសេរីភាពបញ្ចេញមតិ

និស្សិត

អ្នកចូលរួមជាច្រើន បានរាយការណ៍អំពីការតែបន្តឹងពីសំណាក់អាជ្ញាធរ បុគ្គលមានអំណាច សមាជិកគ្រួសារ និងស្ថាប័នអប់រំ ដែលរារាំងយុវជនជាច្រើនក្នុងការបញ្ចេញមតិរបស់ពួកគេ។

> សាកលវិទ្យាល័យជាច្រើនមិនអនុញ្ញាតឲ្យគ្រូ ឬនិស្សិតជជែកគ្នាដោយទូលាយអំពីបញ្ហានយោបាយនោះទេ។

ថ្នាក់គ្រប់គ្រងត្រូវបានគេរាយការណ៍ថា តែងតែធ្វើការតែបន្តឹងលើសេរីភាពបញ្ចេញមតិក្នុងបរិវេណសាកលវិទ្យាល័យ ហើយសាកលវិទ្យាល័យជាច្រើនមិនអនុញ្ញាតឲ្យគ្រូបង្រៀន ឬនិស្សិតជជែកគ្នាដោយទូលាយអំពីបញ្ហានយោបាយនោះទេ។ ពួកគេត្រូវបានរារាំងមិនឲ្យពិភាក្សាអំពីបញ្ហាដូចជាជម្លោះដីធ្លី ដោយសារបញ្ហានេះជារឿងរសើបខាងនយោបាយ។ អ្នកចូលរួមជាច្រើន បានលើកឡើងថា រាល់ការប្រមូលផ្តុំនិស្សិតក្នុងបរិវេណសាកលវិទ្យាល័យ ត្រូវបានថ្នាក់ដឹកនាំរបស់សាកលវិទ្យាល័យឃ្លាំមើល ឬរារាំងដោយសារថា ពួកគាត់ភ័យខ្លាចនិស្សិតនឹងជជែកគ្នាពីរឿងនយោបាយ។

កម្មករ

សេរីភាពបញ្ចេញមតិរបស់កម្មករត្រូវបានគេតែបន្តឹងខ្លាំង។ សិទ្ធិរបស់កម្មករក្នុងការប្រមូលផ្តុំដោយសន្តិវិធីត្រូវបាន គេបដិសេធជាញឹកញាប់ ជាពិសេស នៅពេលដែលកម្មករទាំងនោះមានបំណងចូលរួមបាតុកម្មដោយសន្តិវិធីពាក់ព័ន្ធនឹងជម្លោះការងារ និងទាមទារឲ្យមានការប្រណិប័តន៍ស្មើភាព ឬប្រសើរជាងនេះពីនិយោជក។

ចុងចោទ និងសាក្សី

អ្នកចូលរួមជាច្រើន បានរាយការណ៍ថា ចុងចោទ និងសាក្សីក្នុងករណីសំណុំរឿងព្រហ្មទណ្ឌ ត្រូវបានគេបដិសេធនូវសិទ្ធិក្នុងការបញ្ចេញមតិ។ ជនសង្ស័យ តែងត្រូវបានសន្មតថាមានកំហុស និងសាក្សីសម្រាប់ចុងចោទ តែងត្រូវបានគេបដិសេធសិទ្ធិក្នុងការផ្តល់កស្តុតាងដែលពួកគេចង់ផ្តល់ជូន ហើយត្រូវបានព្រះរាជអាជ្ញាបង្ខំឲ្យប្រគល់តែកស្តុតាងជាក់លាក់ប៉ុណ្ណោះ។

ជនជាតិដើមភាគតិច ស្ត្រី និងមន្ត្រីរាជការ

អ្នកចូលរួមក៏បានយល់ស្របគ្នាដែរថា អាជ្ញាធរជាញឹកញាប់បានរើសអើងមកលើសមាជិកក្រុមជនជាតិដើមភាគតិច ហើយដែលការស្នើសុំផ្សេងៗ ដូចជាបណ្តឹង ឬការបញ្ចេញមតិរបស់ពួកគេតែងតែមិនត្រូវបានយកចិត្តទុកដាក់។ ចំណែកក្នុងចំណោមមន្ត្រីរាជការក៏រងគ្រោះពីការខ្វះសេរីភាពបញ្ចេញមតិដែរ ដោយសារពួកគេចៀសវាងមិននិយាយស្តីពីបញ្ហារស៊ើប ដោយសារតែមានការភ័យខ្លាចថាពួកគេនឹងបាត់បង់មុខតំណែង។ ចំណែកស្ត្រីក៏នៅតែរងផលប៉ះពាល់ដោយសារការតបន្តឹងមកលើសេរីភាពបញ្ចេញមតិរបស់ពួកគេផងដែរ ដែលករណីនេះកើតឡើងនៅក្នុងសង្គម ក៏ដូចជាក្រុមគ្រួសារផងដែរ។

អនុសាសន៍

រដ្ឋាភិបាលគួរតែ៖

- ✓ ធានាដល់ការបកស្រាយ និងអនុវត្តច្បាប់ឲ្យមានប្រសិទ្ធិភាព ជាពិសេសច្បាប់ស្តីពីបាតុកម្ម ដោយសន្តិវិធី។ ជាងនេះទៅទៀត ច្បាប់ទាំងនេះគួរកំណត់ឲ្យបានច្បាស់ពីទីតាំងដែលអាចធ្វើបាតុកម្មបាន ជាពិសេសបញ្ញត្តិពាក់ព័ន្ធនឹងការប្រើប្រាស់ទីលានប្រជាធិបតេយ្យគួរត្រូវបានបកស្រាយឲ្យបានច្បាស់លាស់ (សំខាន់គឺថា កន្លែងទាំងនេះមិនមែនតែជាទីតាំងតែមួយ ដែលអាចរៀបចំបាតុកម្មនោះទេ) ហើយការកំណត់ចំនួនអតិបរមានៃអ្នកចូលរួមបាតុកម្មនៅទីលានប្រជាធិបតេយ្យ នោះគួរត្រូវបានពន្លឿសឲ្យបានច្រើនជាង ២០០ នាក់

- ✓ ធានាថា កម្មវិធីសិក្សារបស់សាលារដ្ឋនឹងដាក់បញ្ចូលនូវកម្មវិធីដែលផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យា និងលទ្ធភាពក្នុងការបញ្ចេញមតិនយោបាយ ព្រមទាំងអាចឲ្យនិស្សិតបានដឹងអំពីសិទ្ធិដែលមិនអាចដកហូតបានដែលធានាក្នុងរដ្ឋធម្មនុញ្ញ

- ✓ ធានាថារាល់គ្រឹះស្ថានអប់រំរបស់រដ្ឋ និងឯកជនធ្វើប្រតិបត្តិការណ៍ក្នុងមជ្ឈដ្ឋានបើកចំហ និងសេរី ដែលគ្រូ និងសិស្សត្រូវបានលើកទឹកចិត្តឲ្យអនុវត្តន៍សិទ្ធិសេរីភាពបញ្ចេញមតិរបស់ខ្លួន

- ✓ លើកទឹកចិត្តមន្ត្រីរាជការឲ្យហ៊ានបង្ហាញព័ត៌មានស្តីពីភាពមិនប្រក្រតីដែលពិត និងជាក់លាក់សម្រាប់ប្រយោជន៍សាធារណៈ និង

- ✓ ធានាថាសំណើ និងពាក្យបណ្តឹងរបស់សមាជិកក្រុមជនជាតិដើមភាគតិច ត្រូវបានអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់។

សេចក្តីសន្និដ្ឋាន

ជាទូទៅ កិច្ចពិភាក្សាតុមូលដែល ម.ស.ម.ក បានរៀបចំក្នុងអំឡុងពេលនៃការអនុវត្តគម្រោងនេះ បានសម្រេចដោយជោគជ័យ ក្នុងការលាតត្រដាងនូវការរឹតបន្តឹងលើសេរីភាពបញ្ចេញមតិ និងការប្រឈមនានារបស់អ្នកចូលរួមមកពីវិស័យផ្សេងៗក្នុងសង្គម និងជីវភាព ដោយសារតែបានអនុវត្តសិទ្ធិទាំងនោះ។ រាល់អនុសាសន៍ទាំងនេះ គឺត្រូវបានលើកឡើងដោយផ្ទាល់ពីសំណាក់អ្នកទាំងឡាយដែលប្រឈមនឹងការរឹតបន្តឹងលើសិទ្ធិ បញ្ចេញមតិ ហើយដែលការលើកឡើងទាំងនេះត្រូវបានរៀបចំធ្វើឡើងក្នុងបរិយាកាសសេរី និងមិនមានការបិទបាំង។ អាស្រ័យហេតុដូចនេះហើយ រដ្ឋាភិបាល និងភាគីពាក់ព័ន្ធគួរយកអនុសាសន៍ទាំងអស់នេះទៅពិចារណា។

ជាការពិតណាស់ ដែលថា មានការវិវត្តន៍មួយចំនួននាពេលថ្មីៗនេះ ពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិ និងយោបល់នៅក្នុងប្រទេសកម្ពុជា ហើយដែលការវិវត្តន៍នេះបានបង្ហាញតាមរយៈលទ្ធផលបោះឆ្នោតនាខែកក្កដា ឆ្នាំ២០១៣ នេះ ហើយដែលបានឆ្លុះបញ្ចាំងនូវជោគជ័យយ៉ាងធំរបស់គណបក្សប្រឆាំង ចំណុចនោះផ្តល់ សេចក្តីសង្ឃឹមសម្រាប់យើងនាពេលអនាគត។ អាត្រានៃការប្រើប្រាស់អ៊ីនធឺណេតនៅកម្ពុជា បានឈានដំហានមួយជាវិជ្ជមាន ពោលគឺជាចរន្តមួយដ៏បូងបំផុត ដែលពលរដ្ឋអាចមានលទ្ធភាពទទួលបានព័ត៌មានដោយសេរី និងមិនមានការគ្រប់គ្រង ព្រមទាំងអាចធ្វើការដៃជែកវែកញែកតាមប្រព័ន្ធអ៊ីនធើណេតផងដែរ។ រដ្ឋាភិបាលគួរតែរក្សានូវវឌ្ឍនភាពនេះ តាមរយៈការអនុវត្តនូវរាល់អនុសាសន៍ដែលបានលើកឡើង ដើម្បីធានាដល់ការប្តេជ្ញាគោរពសិទ្ធិមនុស្សជាអន្តរជាតិនិងក្នុងរដ្ឋធម្មនុញ្ញ ព្រមទាំងដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាផងដែរ។

ឧបសម្ព័ន្ធ ១៖ កិច្ចពិភាក្សាតុមូល

កិច្ចពិភាក្សាតុមូលលើកទី១

កិច្ចពិភាក្សាតុមូលនេះ ត្រូវបានរៀបចំឡើងក្នុងចំណោមពលរដ្ឋខ្មែរដែលជាអ្នកសរសេរប្លុក ដើម្បីពិភាក្សាជុំវិញប្រធានបទសេរីភាពបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធើណេត។ បញ្ហាជាក់លាក់ចំនួន ៣ ត្រូវបានលើកឡើងក្នុងកិច្ចពិភាក្សានោះ៖ ការបិទវែបសាយ បញ្ញត្តិលើអ៊ីនធើណេត និងស្វ័យពិរុទ្ធភាព ក្នុងចំណោមអ្នកសរសេរប្លុកទាំងនោះ។

- កាលបរិច្ឆេទ៖ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១១
- ទីតាំង៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- អ្នកចូលរួម៖ អ្នកសរសេរប្លុក ៤០ នាក់

កិច្ចពិភាក្សាតុមូលលើកទី២

កិច្ចពិភាក្សាតុមូល**នេះ**៖ ត្រូវបានរៀបចំឡើងដោយមានការសហការជាមួយក្លឹបអ្នកការសែតកម្ពុជា។ កិច្ចពិភាក្សាបានផ្តោតលើសេរីភាពបញ្ចេញមតិ និងសារព័ត៌មានបែបប្រពៃណី។ បញ្ហាជាក់លាក់ចំនួន ៤ ត្រូវបានលើកឡើង៖ កម្មសិទ្ធិសារព័ត៌មាន, ក្របខណ្ឌបញ្ញត្តិសារព័ត៌មានបែបប្រពៃណី, សេរីភាពទទួលបានព័ត៌មាន, និងបទបរិហាកេរ្តិ៍។

- កាលបរិច្ឆេទ៖ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២
- ទីតាំង៖ ភោជនីយដ្ឋានទន្លេបាសាក់
- អ្នកចូលរួម៖ អ្នកការសែត អ្នកសារព័ត៌មានទូរទស្សន៍ និងអ្នករាយការណ៍ឲ្យវិទ្យុ ចំនួន ៣០ នាក់

កិច្ចពិភាក្សាតុមូលលើកទី៣

កិច្ចពិភាក្សាតុមូលលើកទី៣ ត្រូវបានរៀបចំឡើងដើម្បីកៀងគរអ្នកតស៊ូមតិខាងសេរីភាពបញ្ចេញមតិ រាប់បញ្ចូលទាំងតំណាងអង្គការសង្គមស៊ីវិល មានសហជីព អង្គការ និងបណ្តាញយុវជន។ កិច្ចពិភាក្សាផ្តោតលើបញ្ហាសេរីភាពបញ្ចេញមតិ និងច្បាប់សេរីភាពទទួលបានព័ត៌មាន។

- ❖ កាលបរិច្ឆេទ៖ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២
- ❖ ទីតាំង៖ ភ្នំពេញ ប្រទេសកម្ពុជា
- ❖ អ្នកចូលរួម៖ សមាជិកបណ្តាញយុវជន និងអង្គការចំនួន ៣០ នាក់

កិច្ចពិភាក្សាតុមូលលើកទី៤

កិច្ចពិភាក្សាតុមូលលើក**នេះ** ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីសំណាក់អ្នកការពារសិទ្ធិមនុស្សមកពី ៣ ប្រភេទ៖ សកម្មជនសហគមន៍ អ្នកសារព័ត៌មាន និងមេធាវី។ ក្រុមនីមួយៗបានពិភាក្សាលើបញ្ហាដែលបានកើតឡើងជាញឹកញាប់ក្នុងវិស័យការងាររបស់ក្រុមខ្លួន។ បញ្ហាជាក់លាក់ដែលត្រូវបានលើកឡើង រួមមានការដៅមុខសញ្ញារបស់អាជ្ញាធរទៅលើសកម្មភាពយុទ្ធនាការ ការសម្តែតគំរាម និងការគំរាមកំហែងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស ប្រព័ន្ធតុលាការត្រូវបានគេប្រើប្រាស់ដើម្បីតបន្តឹងលើសេរីភាពបញ្ចេញមតិ និងកង្វះលទ្ធភាពទទួលបានព័ត៌មាន។

- ❖ កាលបរិច្ឆេទ៖ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១២
- ❖ ទីតាំង៖ សណ្ឋាគារ អ៊ឹមគើរៀល ហ្គាឌិន
- ❖ អ្នកចូលរួម៖ សកម្មជន មេធាវី អ្នកសារព័ត៌មាន និងបុគ្គលិកអង្គការចំនួន ៤០ នាក់

កិច្ចពិភាក្សាតុមូលលើកទី៥

កិច្ចពិភាក្សាលើកទី៥ បានវិលទៅរកប្រធានបទសេរីភាពខាងអ៊ីនធឺណេតវិញ។ អ្នកចូលរួម រាប់បញ្ចូលទាំងអ្នកសរសេរប្លុក អ្នកប្រើប្រាស់បណ្តាញសង្គម និងអ្នកនិយមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ហើយពួកគេបានជជែកលើបញ្ហាជាក់លាក់ចំនួន ៣៖ ការត្រួតពិនិត្យខ្លួនឯងក្នុងចំណោមអ្នកសរសេរប្លុក ការប្រើប្រាស់និងជម្រើសភាសាក្នុងការសរសេរប្លុក (ខ្មែរ ឬអង់គ្លេស) និង បញ្ញត្តិផ្នែកអ៊ីនធើណេត។

- ❖ កាលបរិច្ឆេទ៖ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣
- ❖ ទីតាំង៖ មជ្ឈមណ្ឌលវប្បធម៌អាល្លឺម៉ង់កម្ពុជា
- ❖ អ្នកចូលរួម៖ បុគ្គលិកអង្គការ អ្នកសរសេរប្លុក អ្នកសារព័ត៌មានចំនួន ៤០ នាក់ និងតំណាងមកពីរដ្ឋាភិបាល ១ រូប

កិច្ចពិភាក្សាតុមូលលើកទី៦

កិច្ចពិភាក្សាតុមូលចុងក្រោយត្រូវបានរៀបចំឡើងរវាងបុគ្គលិកអង្គការសង្គមស៊ីវិល អ្នកសរសេរប្លុក អ្នកសារព័ត៌មាន និងនិស្សិត។ មិនមានបញ្ហាជាក់លាក់ត្រូវបានលើកមកពិភាក្សានោះទេ តែអ្នកចូលរួមបានលើកយកបញ្ហាពាក់ព័ន្ធនឹងច្បាប់ ការត្រួតពិនិត្យដោយខ្លួនឯង សេរីភាពខាងអ៊ីនធឺណេត និងការតបន្តឹងទូទៅលើសេរីភាពបញ្ចេញមតិ។

- កាលបរិច្ឆេទ៖ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣
- ទីតាំង៖ ភោជនីយដ្ឋានខ្មែរសុរិន
- អ្នកចូលរួម៖ សរុប ៥៤ នាក់ ជាបុគ្គលិកអង្គការសង្គមស៊ីវិល អ្នកសារព័ត៌មាន អ្នកសរសេរប្លុក និងនិស្សិត

សិក្ខាសាលាបូកសរុប

សិក្ខាសាលាបូកសរុប ដែលរៀបចំឡើងដើម្បីបូកសរុបនូវលទ្ធផលនៃកិច្ចពិភាក្សាតុមូល ដែលមានការចូលរួមពីសំណាក់ សមាជិកក្រុមជនជាតិដើមភាគតិច សិស្ស និងបុគ្គលិក អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល។ សិក្ខាសាលានេះត្រូវបានរៀបចំឡើង ដើម្បីរួមបញ្ចូលនូវរបកគំហើញដែលបានរកឃើញ និងជំរុញឲ្យពិភាក្សាយ៉ាងទូលំទូលាយ ជុំវិញ បញ្ហាសេរីភាពបញ្ចេញមតិជាទូទៅ។

- កាលបរិច្ឆេទ៖ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣
- ទីតាំង៖ សណ្ឋាគារអ៊ីនធើខនធើណិនថល ភ្នំពេញ
- អ្នកចូលរួម៖ សរុប ១០០ នាក់ ជានិស្សិត បុគ្គលិកអង្គការសង្គមស៊ីវិល និងសមាជិកក្រុមជនជាតិដើមភាគតិច